Box 13 fn ~~150~~ 157 continue ~~(cont)~~

~~151~~ ~~163~~ ~~175~~ ~~189 (last file)~~

~~152~~ ~~164~~ ~~185~~ ~~190~~

~~154~~ ~~168~~ 197

~~155~~ ~~177~~ ~~181~~

~~156~~ ~~186~~ ~~188~~

*PROGRAMME NUMBER :*
*PRODUCED BY : KUY HUOT*
*EDITED BY : V; TSIORKO & STEVEN S. PAK*
*DURATION :*
*DATE :*

159K
29' 19"

**SUMMARY**

*- CAMBODIAS' LIFE AFTER PARIS PEACE AGREEMENT*

*- COW AND BUFFALO DISEASE IN CAMBODIA*

*- MEANS OF PREVENTING FROM DAMAGED RICE CROP*

*- CAMBODIAN SONGS*

**មាតិកា**

- ជីវភាពប្រជាពលរដ្ឋខ្មែរ ក្រោយមានកិច្ចព្រមព្រៀងសន្តិភាពនាទីក្រុងប៉ារីស
- ជំងឺសារទឹកគោ ក្របី
- វិធីសាស្ត្រការពារទុបទល់នឹងសត្វល្អិតដែលបំផ្លាញលើដំណាំស្រូវ
- ចំរៀងខ្មែរ

22/3/93

PAGE : 1

SAMRECH :

លោកអ្នកនាងស្ដាប់ជាទីមេត្រី ! មុននឹងជំរាបជូននូវការអធិប្បាយមួយស្ដីពីជីវភាពប្រជាពលរដ្ឋខ្មែរក្រោយមានកិច្ចព្រមព្រៀងសន្តិភាពនាទីក្រុងប៉ារីស យើងខ្ញុំសូមអញ្ជើញលោកអ្នកនាងកំសាន្តរីករាយជាមួយចំរៀងខ្មែរមួយបទក្រោមចំណងជើងថា ៖

« [illegible] »

SAKHAN :

លំដាប់តទៅនេះ សូមអញ្ជើញលោកអ្នកនាងស្ដាប់នូវការអធិប្បាយមួយស្ដីពីជីវភាពប្រជាពលរដ្ឋខ្មែរក្រោយមានកិច្ចព្រមព្រៀងសន្តិភាពនាទីក្រុងប៉ារីស ។

## ការអធិប្បាយស្តីពីជីវភាពប្រជាពលរដ្ឋខ្មែរ
## ក្រោយពីមានកិច្ចព្រមព្រៀងសន្តិភាពនាទីក្រុងប៉ារីស

វិទ្ធី :

ក្រោយពីភាគីកម្ពុជាទាំងបួននិងបណ្តាប្រទេសមួយចំនួនបានចុះហត្ថលេខានាទីក្រុងប៉ារីសនៅថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ លើកិច្ចព្រមព្រៀងស្តីពីដំណោះស្រាយរួមមួយនៃជំលោះនោះមកយើងសង្កេតឃើញនៅក្នុងប្រទេសកម្ពុជាស្ទើរតែគ្រប់ទីកន្លែងមានការរីកចំរើនគួរកត់សំគាល់ ។ ខាងវិស័យស្ថាបនា ដូចជាសណ្ឋាគារ ភោជនីយដ្ឋាន ហាងលក់ទំនិញនិងអាគារសាធារណៈផ្សេងៗ មានការជឿនលឿនហួសពីការស្មាន ជាពិសេសនៅទីក្រុងភ្នំពេញ អាគារខ្លះត្រូវបានជួសជុលកែលំអជាថ្មី ខ្លះទៀតកំពុងតែកសាងជាបន្តបន្ទាប់ ។ ប្រការនេះបញ្ជាក់ឲ្យឃើញអំពីទឹកចិត្តរបស់ពលរដ្ឋកម្ពុជានៅក្នុងប្រទេស និងនៅក្រៅប្រទេស ព្រមទាំងជនបរទេស ជឿជាក់ចំពោះដំណើរការសន្តិភាពនៅកម្ពុជាដែលរៀបចំឡើងដោយអ៊ុនតាក់ ។

ធីតា :

ចាប់តាំងពីដំណើរការដែលមានអ៊ុនតាក់រៀបចំកន្លងមកដល់ពេលនេះ ជិត២០០ក្រុមហ៊ុនបានបណ្តាក់ទុននៅក្នុងប្រទេសកម្ពុជាយើង ។ តាមស្ថិតិដែលគេដឹងក្រុមហ៊ុនទាំងនោះមកពីប្រទេសជាង ២០ នៅជុំវិញពិភពលោកដូចជា៖ Hong-Kong -Singapore - Thailand -Taiwan - American - Japan និង បណ្តាប្រទេសជាច្រើនទៀត ។ល។

ក្រុមហ៊ុនទាំងនោះបានបណ្តាក់ទុនលើគម្រោងជាង៣០០គម្រោងដូចជា៖ ក្នុងការបណ្តាក់ទុនលើផ្នែកសណ្ឋាគារ ផលិតផលកសិកម្ម កេស្ទជះ ដែក និង ស៊ីម៉ង់ ហើយនិងការរុករកធនធានធម្មជាតិក្នុងប្រទេសផងដែរ ។

វិទ្ធី :

អ្នកសេដ្ឋកិច្ចរបស់អ៊ុនតាក់បានបញ្ជាក់បង្ហាញថា៖ « ការវិនិយោគទុនបរទេសបណ្តាលឲ្យមាននិកាសថ្មីមួយសំរាប់ប្រទេសកម្ពុជា ។ មានន័យថា៖ វាជាមូលដ្ឋានមួយដ៏សំ

ទាន់ដែលធ្វើឲ្យប្រទេសកម្ពុជាទទួលបានពន្ធដារប្រចាំឆ្នាំយ៉ាងច្រើន ។ អ៊ុនតាក់គឺត្រូវមានការទាក់ទងក្នុងការដាក់វិធានការដើម្បីបង្កើននូវបរិយាកាសធ្វើវិនិយោគទុន និងធានានូវបរិយាកាសខាងវិស័យពាណិជ្ជកម្មឲ្យកាន់តែល្អប្រសើរ ។

ធីតា :

ទន្ទឹមនឹងការរីកចំរើនលើវិស័យទាំងនោះ បើយើងក្រឡេកមើលទៅកម្មករ កសិករជាពិសេសប្រជាពលរដ្ឋដែលនៅជនបទ និងនៅតំបន់ដាច់ស្រយ៉ាលវិញ យើងនឹងឃើញមានការខុសគ្នាយ៉ាងខ្លាំងរវាងអ្នកធ្វើពាណិជ្ជកម្ម និងអ្នកធ្វើស្រែចំការ រវាងអ្នកនៅទីក្រុង និងអ្នកនៅជនបទ ។ សព្វថ្ងៃនេះកម្មករ អ្នកធ្វើស្រែចំការ បុគ្គលិកដែលបំរើការងារនៅតាមក្រសួងនានាមួយចំនួននៅក្នុងប្រទេសកម្ពុជា បានជួបប្រទះនូវការលំបាកយ៉ាងខ្លាំងក្នុងជីវភាពរស់នៅ ដោយសារការចុះថ្លៃនៃប្រាក់រៀល និងដោយសារការមិនមានតុល្យភាពរវាងតំលៃទំនេញ ដែលនាំចូលពីប្រទេសក្រៅ និងផលិតផលកសិកម្មដែលកសិករយើងផលិតនៅក្នុងស្រុក ។

វិទ្ធី :

ក្នុងសំភាសន៍ជាមួយលោកតា ម៉ុក សារឿន ជាអតីតបុគ្គលិកចែកផ្សាយការសែតកម្ពុជាបានមានប្រសាសន៍ជំរាបដល់វិទ្យុអ៊ុនតាក់យើងថា ៖

« ប្រជាជនមានការលំបាកជាពន្លពេក ដែលរបស់របរទាំងប៉ុន្មានដែលយកទៅលក់នៅទីផ្សារ ទុបទល់នឹងជីវភាពរស់នៅដោយពិបាក អាស្រ័យប៉ុន្មានថ្ងៃនេះទៀតគឺលុយក្រដាស៥០រៀល ឈ្មួញធ្វើព្យុះធ្វើផ្គរភ្លៀង ចំនួន៣ថ្ងៃទើបទើបបានរដ្ឋចេញផ្សាយផព្រើលុយ៥០រៀលនោះវិញ ក៏ប៉ុន្តែនៅទីផ្សារសព្វថ្ងៃនេះ គ្មាននរណាយកក្រដាស៥០រៀលនោះទៅចាយទេ ដោយគេបានយល់ដឹងថាលុយនោះមិនចាយ អាស្រ័យហេតុនេះប្រជាជននៅទីផ្សា គ្រប់ជនបទទាំងអស់មានការពិបាកវេទនាដោយសារលុយនេះឡើងថ្លៃហួសកំរិត ។ ខ្ញុំបានសំណូមពរដល់អ៊ុនតាក់ជួយដោះស្រាយអំពីរឿងលុយកាក់ហ្នឹង កុំឲ្យឈ្មួញធ្វើព្យុះធ្វើផ្គរតទៅទៀតហើយធ្វើឲ្យតំលៃប្រាក់រៀលនឹងនរ ។ »

7'68·

ធីតា :

ចំណែកបងស្រី អ៊ុង ផាណាដែលមានប្តីជាកម្មករបានជំរាបដល់វិទ្យុអ៊ិនតាក់ ថា ៖

« ចំពោះបញ្ហាជីវភាពសព្វថ្ងៃ ចំពោះទំនេញសព្វថ្ងៃឡើងទ្វេមួយជាពីរ កំរៃដែលរកបានសព្វថ្ងៃមិនអាចដូរបានទិញ ឬរបស់អ្វីពីឈ្មួញទំនេញឡើងថ្លៃឡើយ ។ សព្វថ្ងៃរកបានតែម៉ាហូប។ ខ្ញុំចង់សំណូមពរដល់ក្រុមអ៊ិនតាក់ឲ្យជួយដល់ប្រជាជន ដែលនៅតាមជនបទ ដែលគ្នាធ្វើស្រែចំការរកអ្វីមិនបាន សូមឲ្យក្រុមអ៊ិនតាក់ជួយសំរួលដល់ប្រជាជននៅតាមជនបទ ។ »

SAMRECH :

អំបាញ់មិញនេះលោកអ្នកនាងទើបនឹងបានស្តាប់នូវការអធិប្បាយមួយស្តីពីជីវភាពប្រជាពលរដ្ឋខ្មែរក្រោយពីមានកិច្ចព្រមព្រៀងសន្តិភាពនាទីក្រុងប៉ារីស ។ លំដាប់តទៅនេះយើងខ្ញុំសូមអញ្ជើញលោកអ្នកនាងកំសាន្តរីករាយជាមួយចំរៀងខ្មែរដ៏ពិរោះមួយបទក្រោមចំណងជើងថា « [illegible] »

SAKHAN :

លំដាប់តទៅនេះ សូមអញ្ជើញលោកអ្នកនាងស្តាប់នូវអត្ថបទកសិកម្មមួយស្តីពី និមិត្តហេតុ រោគសញ្ញា ការព្យាបាល និងវិធានការណ៍ការពារលើជំងឺសារទឹកគោ ក្របី ។

## ជំងឺសារទឹកគោ ក្របី

Sopheap ~~RITHY~~ :

ជំងឺសារទឹក ឬគ្រុនឈាមគោ ក្របី ជាជំងឺឆ្លងមួយយ៉ាងកាចសាហាវ ។ នៅអាស៊ីអាគ្នេយ៍ ជារៀងរាល់ឆ្នាំ ជំងឺនេះច្រើនកើតនៅរដូវភ្លៀងធ្លាក់ ។ គេបានចាត់ទុកជម្ងឺនេះជាជំងឺឆ្លងបំផុតសំរាប់គោ ក្របី ។ ជំងឺនេះច្រើនកើតឡើងនៅតាមតំបន់ដីសណ្ដរ តំបន់មានស្ទឹងបឹងបួរ និងច្រកភ្នំ ជាពិសេសនៅទីណាដែលគេប្រើប្រាស់ក្របីដើម្បីធ្វើស្រែ ។ ប៉ុន្តែជួនកាលជំងឺនេះក៏អាចកើតឡើងនៅតំបន់ដីស្ងួតដែរ ដោយគេមិនអាចកំណត់ពេលវេលាបានផង។

SOTHARY :

ជំងឺនេះមានលក្ខណៈរាតត្បាតខ្លាំងក្នុងកាលៈទេសៈ ដែលធាតុអាកាសប្រែប្រួល ហើយមិនសមស្របនឹងតំរូវការរបស់សត្វ ។ ការហេវហត់បណ្ដាលមកពីការដឹកនាំឆ្ងាយហួសប្រមាណ គឺជាមូលហេតុដែលបណ្ដាលឲ្យសត្វទទួលជំងឺសារទឹក ។ ការរងារញាក់ចំណីខ្វះគុណភាព ការផ្លាស់ប្ដូរចំណីអាហារ ការចាក់ថ្នាំការពារជំងឺដទៃទៀត ក៏សុទ្ធតែជាមុលហេតុបណ្ដាលឲ្យជំងឺសារទឹកកើតមានឡើងដែរ ។

< ភ្លេងកាត់ >

Sopheap ~~RITHY~~ :

ចំពោះភាគច្រើននៃគោនិងក្របី ជំងឺនេះច្រើនមានសភាពសាហាវ ដែលបណ្ដាលឲ្យសត្វងាប់ក្នុងរយៈពេល ៦ទៅ២៤ម៉ោង ក្រោយពីមានរោគសញ្ញាមក ។ ដំបូងសត្វគ្រុនក្ដៅ ស្មោរ មិនចង់ឈានជើងដើរ បន្ទាប់មកមានហៀរទឹកមាត់ និងទឹកសំបោរ ។ តាមធម្មតាការហើមតែងសំគាល់ឃើញមានជុំវិញបំពង់ក ហើយរាលដាលទៅដល់ចន្លោះជើងមុខ ឡើងដល់ត្រង់ត្រចៀក និងជួនកាលកើតនៅជុំវិញក្បាលទៀតផង ។ អណ្ដាតអាចឡើងហើមតឹង និងលៀនចេញមកក្រៅ ។ ឯការដកដង្ហើមក៏ពិបាក ហើយសត្វច្រើនតែងាប់ក្នុងរយៈពេលខ្លី ៨ទៅ៥ម៉ោង។ ការជាឡើងវិញ ជាការកំរ ពិសេសចំពោះក្របី ។

SOTHARY :

ការព្យាបាលត្រូវចាប់ផ្ដើមភ្លាម ទន្ទឹមនឹងសត្វចាប់ផ្ដើមបង្ហាញរោគសញ្ញា ។ ជួនកាលសត្វអាចជាបានដោយប្រើថ្នាំ ស៊ុលហ្វាឌីមីឌីន ស៊ុលហ្វាពីរីឌីន ឬថ្នាំអង់ទីប៊ីយ៉ូទីក

*ដែលមានប្រសិទ្ធភាពលើមេរោគច្រើនមុខ។*

RITHY :

*មានតែការចាក់ថ្នាំការពារជំងឺប៉ុណ្ណោះទេ ដែលអាចផ្ដល់នូវប្រសិទ្ធភាពក្នុងការទុបទល់នឹងជំងឺនេះបាន។ ត្រូវយកសត្វគោ ក្របីទៅចាក់ថ្នាំឲ្យបានមុនរដូវភ្លៀងធ្លាក់ ។ ជាការប្រសើរគួរចាក់ថ្នាំបង្ការឲ្យបានពីរដងក្នុងមួយឆ្នាំ ។ ការចាក់ថ្នាំបង្ការរោគប្រចាំឆ្នាំឲ្យមេគោនិងក្របី តែងផ្ដល់កិរិតការពារយ៉ាងខ្ពស់ដល់កូនវា ។*

SAMRECH :

*លោកអ្នកនាងស្ដាប់ជាទីមេត្រី ! ជាបន្តទៅទៀតនេះសូមអញ្ជើញលោកអ្នកនាងកំសាន្តរីករាយជាមួយចំរៀងមួយបទក្រោមចំណងជើងថា < [illegible] >។*

SAKHAN :

*ជាបន្តទៅទៀតនេះ សូមអញ្ជើញលោកអ្នកនាងស្ដាប់នូវសេចក្ដីរាយការណ៍មួយស្ដីពីវិធីសាស្ត្រការពារទុបទល់នឹងសត្វល្អិតបំផ្លាញលើដំណាំស្រូវ ។*

## វិធីសាស្ត្រការពារទុបទល់នឹងសត្វល្អិតបំផ្លាញលើដំណាំស្រូវ

សុភាព :

ក្នុងរយៈពេលលូតលាស់របស់ដំណាំស្រូវ យើងតែងជួបប្រទះឃើញសត្វល្អិតច្រើនប្រភេទចូលស៊ីបំផ្លាញ ដូចជា ដង្កូវបំពង់កាត់ស្លឹក ដង្កូវមូរស្លឹក ដង្កូវស៊ីរូងដើម ដង្កូវស៊ីរូងលឿង ដង្កូវស៊ីរូងឆ្នូត សត្វក្តាម សត្វបក្សី និងសត្វកណ្តុរជាដើម ។ ក្នុងការកំចាត់សត្វល្អិតចង្រៃទាំងនេះយើងអាចប្រើប្រាស់ថ្នាំសំលាប់ទៅតាមដំណាក់កាលនិមួយៗ ហើយថ្នាំដែលមានប្រសិទ្ធផាពជាងគេគឺ ៖

-ថ្នាំអាហ្សូឌ្រីន-៦០% ៣-៤ស្លាបព្រា លាយជាមួយទឹកចំនួនមួយប៉ោតប្រេងកាត ឬធុងបាញ់ថ្នាំចំនួន១៧លីត្រ។ ថ្នាំនេះបំពុលក្តាមបានដែរ ។

-ថ្នាំឌីក្លរហ្វូស ប្រើ៤ស្លាបព្រា លាយទឹកចំនួនមួយប៉ោតប្រេងកាត ឬធុងបាញ់ថ្នាំចំនួន១៧លីត្រ ។

-ថ្នាំបៀកឡាន-១០% ត្រូវលាយជាមួយដីខ្សាច់ដើម្បីឲ្យថ្នាំនេះព្រាចបានស្មើល្អ ។ ថ្នាំនេះអាចធ្វើឲ្យត្រី និងក្តាមអាចងាប់ទៀតផង ។

ពេលវេលាមានប្រសិទ្ធភាពក្នុងរយៈពេលនៃការលូតលាស់ដំណាំស្រូវ ត្រូវបាញ់ថ្នាំចំនួនបីដង ៖ លើកទីមួយ ក្រោយពេលស្ទូងបាន២០ថ្ងៃ លើកទីពីរ ពេលដែលស្រូវមានអាយុ៥០ថ្ងៃ លើកទីបី ពេលដែលស្រូវមានអាយុ៨០ថ្ងៃ ។

សុថារី :

ក្នុងការកំចាត់ដង្កូវបំពង់កាត់ស្លឹក គេក៏អាចអនុវត្តន៍បានដែរ ហើយតែងទទួលលទ្ធផលល្អគឺ ធ្វើថ្នាលគោក ស្ទូងសំណាបដើមចាស់ បញ្ចូលទឹកក្នុងស្រែ ឬថ្នាលឲ្យលិចចុងស្រូវ ហើយកៀរដង្កូវចេញ ។ ក្នុងការកំចាត់ដង្កូវស៊ីរូងដើម ត្រូវភ្ជួររាស់ដីដោយបញ្ចូលទឹកពន្លិច ផ្លាស់ប្តូរមុខដំណាំ សំអាតស្មៅដែលដុះក្នុងស្រែ និងតាមភ្លឺស្រែ ប្រមូលកាកសំណល់ផ្សេងៗដុតចោលបន្ទាប់ពីច្រូតកាត់រួច ឬច្រូតឲ្យជិតគល់ និងជ្រើសរើសពូជដែលធន់ទ្រាំ ។ វិធីកំចាត់នេះ គឺជាវិធីមួយដ៏ល្អប្រសើរបំផុតសំរាប់ការដាំដុះដំណាំស្រូវ ដូចជាអាចរក្សាបាននូវសត្វល្អិតមានប្រយោជន៍ មិនបំពុលសត្វពាហនៈ មនុស្ស និងបំពុលបរិយាកាសជុំវិញ ជាពិសេសកសិករ ពុំចាំបាច់ចំណាយប្រាក់ច្រើនដើម្បីទិញថ្នាំពុលនោះផង។

សុភាព :

ក្នុងការកំចាត់ក្ដាម គេអាចប្រើទ្រូដាក់នុយ ដូចជាបាយ ឬកាកសំណល់ផ្សេងៗ ទៅដាក់នៅតាមស្រែ ឬបាញ់ថ្នាំអង់ទ្រីន-២០% ដោយលាយជាមួយទឹកឲ្យបានច្រើនបាញ់នៅតាមភ្លឺស្រែ និងតាមរូងក្ដាម។ ចំពោះការកំចាត់សត្វកណ្ដុរ គេអាចកំចាត់វាដោយប្រើអន្ទាក់នៅតាមភ្លឺស្រែ និងដោយប្រើថ្នាំរ៉ាទុយ រ៉ាហ្វារីន ឬផុសស្វៀដីហ្សាំងលាយជាមួយនុយមួយចំនួនដូចជា ពោតស្ងោរ បាយ សណ្ដែកស្ងោរ ដាក់នៅតាមភ្លឺស្រែ ឬដាក់នៅតាមគម្ពោតព្រៃនៅជិតៗស្រែ ឬនៅតាមរន្ធឲ្យបានច្រើនកន្លែងបន្តិច ។

ក្នុងសំភាសន៍ជាមួយលោក ប៉ែន វុធជាអ្នកទទួលខុសត្រូវផ្នែកការពារដំណាំនៅស្ថានីយន៍ស្ទឹងមានជ័យ បានជំរាបដល់វិទ្យុអ៊ិនតាក់យើងឲ្យបានដឹងថា ៖
« ក្នុងអាយុកាលស្រូវនៅក្នុងថ្នាលសំណាបនៅឡើយ តែងរងនូវការបំផ្លិចបំផ្លាញពីដង្កូវហ្វូង និងមមុងជញ្ជក់ជ័រស្រូវ ។ ក្នុងដំណាក់កាលនេះជាទូទៅ កសិករ តែងប្រើវិធានការសមញ្ញរួមផ្សំនឹងការប្រើថ្នាំពុល ។ កន្លងមកចំពោះការបំផ្លាញដង្កូវហ្វូង យើងតែងជីកប្រឡាយកាត់មុខដង្កូវហ្វូង រួចពោយផេះនៅបាតប្រឡាយ ហើយដង្កូវក៏ធ្លាក់ចូលទៅក្នុងហ្នឹង យើងប្រមូលដង្កូវនោះទៅកប់ចោលទៅ ។ ចំពោះមមង់វិញ ដូចជានៅលើស្រូវក្នុងខេត្តស្វាយរៀងនៅក្នុងឆ្នាំ១៩៩១ ប្រជាជនយើងគាត់យកម្ទេសបុកលាយជាមួយទឹកហើយព្រោចលើដំណាំស្រូវ ។ ក្នុងដំណាក់កាលក្រោយពេលស្ទូងរួច សន្ទូងតែងរងនូងការបំផ្លាញពីសំណាក់ដង្កូវបំពង់កាត់ស្លឹក សញ្ញានៃការបំផ្លាញរបស់វាគឺនៅចុងស្លឹកមានពណ៌ស វិធានការណ៍ការពារគឺបង្ហូរទឹកចេញពីស្រែ ព្រោះដង្កូវនោះឯកដង្ហើមយកអុកស៊ីសែនពីក្នុងទឹក បើអត់ទឹកវានឹងស្លាប់ ។

សុថារី :

ក្រោយពេលស្ទូងរួចនេះដែរ គេក៏សង្កេតឃើញមានដង្កូវមូរស្លឹក និងដង្កូវស៊ីរូងដើមដែលបំផ្លាញលើសន្ទូង ។ លោកប៉ែន វុធបានបញ្ជាក់បន្ថែមទៀតថា ៖
« ក្នុងការកំចាត់សត្វល្អិតចង្រៃខាងលើកសិករនិយមប្រើថ្នាំពុលគីមីដូចជា AZODRINE METHYL DE PARATHION DICHLOPHOS ប៉ុន្តែគាប្រើប្រាស់ថ្នាំនេះកន្លងមក មានការខុសឆ្គងលើកវិតប្រើប្រាស់ដែលបណាលឲ្យមានគ្រោះថ្នាក់ដល់សត្វពាហនៈ និងបំពុលបរិយាកាស »